# គោលគំនិតបី នៃការតស៊ូដោយពលរដ្ឋ៖ សាមគ្គីភាព ផែនការ វិន័យ

# The Trifecta of Civil Resistance: Unity, Planning, Discipline

**Hardy Merriman**

opendemocracy.net, November 19, 2010

Translation: August 2020

# គោលគំនិតបី នៃការតស៊ូដោយពលរដ្ឋ៖ សាមគ្គីភាព ផែនការ វិន័យ

លក្ខណៈបី ដែលចាត់ទុកថាអាចធ្វើឱ្យមានភាពខុសគ្នារវាងជោគជ័យ និងបរាជ័យ នៃចលនាអហិង្សាជុំវិញពិភពលោក៖ សាមគ្គីភាព ផែនការ និងវិន័យអហិង្សា។

ដោយ ហាឌី មេរីមែន
១៩ វិច្ឆិកា ២០១០

អំពីអ្នកនិពន្ធ៖
លោក ហាឌី មេរីមែន ជានាយកកម្មវិធីស្រាវជ្រាវរបស់ មជ្ឈមណ្ឌលអន្តរជាតិអំពីជម្លោះអហិង្សា (ICNC) ពីឆ្នាំ២០០៥ - ២០០៧។ គាត់បានកែសម្រួលសៀវភៅ "ការប្រតិបត្តិការតស៊ូដោយអហិង្សា៖ ការអនុវត្តនៅសតវត្សរ៍ទី២០ និងសក្តានុពលនៅសតវត្សរ៍ទី២១" ដោយលោកយីន សាប ហើយក៏ជាសហអ្នកនិពន្ធសៀវភៅ "មគ្គុទេសន៍សម្រាប់ការតស៊ូដោយអហិង្សាដ៏មានប្រសិទ្ធភាព"។

តើអ្វីដែលធ្វើឱ្យការតស៊ូអហិង្សាមានប្រសិទ្ធភាព?

ប្រសិនបើយើងទទួលយកការពិតជាក់ស្តែងថានៅក្នុងនយោបាយ «អំណាចនឹងមិនត្រូវបានផ្តល់ឱ្យនោះទេ វាតែងតែត្រូវបានចាប់យក» សេចក្តីសន្និដ្ឋាន គឺចាំបាច់ដែលថាចលនាអហិង្សាក្នុងប្រវត្តិសាស្ត្រ ទទួលបានជោគជ័យ ដោយសារតែថាចលនានេះមានអំណាចលើសលុបជាងគូបដិបក្ខ។

សេចក្តីសន្និដ្ឋាននេះ មានភាពចម្រូងចម្រាស់ ហើយក៏បានបើកចំហឱ្យមានការសួរដោយផ្ទាល់អំពី ការសន្មតដ៏ទូលំទូលាយថាអំណាចជាមូលដ្ឋានបានមកពី ការគ្រប់គ្រងនូវធនធានសម្ភារៈ និងសមត្ថភាពក្នុងការបង្កហិង្សា។ ប្រសិនបើការសន្មតនេះពិតជាត្រឹមត្រូវទាំងស្រុងនោះ ចលនាអហិង្សាច្បាស់ជានឹងបរាជ័យ បើធ្វើឡើងប្រឆាំងនឹងគូប្រជែងដែលមានអាវុធល្អជាង និងធនធានច្រើនជាង។ ក៏ប៉ុន្តែ អ្វីដែលប្រវត្តិសាស្ត្របានបង្ហាញនោះ គឺថាបន្ទាត់ពេលវេលានៃការតស៊ូអហិង្សាដែលទទួលបានជោគជ័យជាច្រើនមើលទៅជាងមួយសតវត្សរ៍ មានអ្នកដឹកនាំ និងមូលហេតុចម្រុះជាច្រើនដូចមនុស្សជាតិដែរ។ នេះជាឧទាហរណ៍ខ្លះៗ៖

- ក្នុងទស្សវត្សរ៍ទី៣០ និង ៤០ ជនជាតិឥណ្ឌាទទួលបានឯករាជ្យភាពរបស់ខ្លួន តាមរយៈការចូលរួមក្នុងការមិនសហការណ៍ដ៏សម្បើម (ពហិកាសេដ្ឋកិច្ច ពហិកាសាលារៀន កូដកម្ម ការមិនបង់

ពន្ធ ការបដិសេធច្បាប់រដ្ឋ ការលោឈប់) ដែលគំរាមធ្វើឱ្យឥណ្ឌាមិនអាចគ្រប់គ្រងបាន ហើយជាចុងក្រោយ ធ្វើឱ្យជនជាតិអង់គ្លេសសម្រេចចិត្តចាកចេញ

- ក្នុងអំឡុងទស្សវត្សរ៍ទី៥០ និង៦០ ចលនាសិទ្ធិពលរដ្ឋរបស់សហរដ្ឋអាមេរិក យកឈ្នះសិទ្ធិស្មើភាពគ្នា តាមរយៈយុទ្ធនាការអហិង្សា ដូចជា ពហិកាឡានក្រុង នៅម៉ុងត៍ហ្គូមេរី និង ការអង្គុយកូដកម្មនៅកន្លែងបាយថ្ងៃត្រង់ នៅណាស៍វីល ដែលកេងចំណេញពីចំណុចខ្សោយនៃប្រព័ន្ធបែងចែកវណ្ណៈក្នុងស្ថាប័ន ហើយក៏បានទាក់ទាញអ្នកគាំទ្រពេញប្រទេស
- ក្នុងអំឡុងឆ្នាំ១៩៦៥ និង ១៩៧០ សហជីពកម្មករចម្ការរួបរួម បានរីកធំជាត់ពីស្ថាប័នតូច និងគ្មានការគាំទ្រថវិកាច្បាស់លាស់ ទៅជាស្ថាប័នថ្នាក់ជាតិ តាមរយៈការប្រើប្រាស់ដោយជោគជ័យនូវកូដកម្ម និងពហិកាប្រឆាំងនឹងចម្ការទំពាំងបាយជូរនៅកាលីហ្វ័រញ៉ា
- នៅក្នុងឆ្នាំ១៩៨៦ នៅហ្វីលីពីន សកម្មជនចូលរួមជាមួយនឹងយោធាដែលចុះចូល ដើម្បីប្រមូលផ្តុំមនុស្សរាប់លាននាក់ធ្វើបាតុកម្មប្រឆាំងនឹងជនផ្តាច់ការដែលគាំទ្រដោយសហរដ្ឋអាមេរិក ហ្វឺឌីណាន់ ម៉ាកូស។ ជម្រើសរបស់លោកកាន់តែថយចុះ ដោយសារតែការបះបោរអហិង្សា ពេលនោះលោកម៉ាកូស បានគេចចេញពីប្រទេស
- ក្នុងឆ្នាំ១៩៨៨ ជនជាតិស៊ីលី បានយកឈ្នះភាពភ័យខ្លាចដែលត្រូវបានបណ្តុះដោយជនផ្តាច់ការឃោរឃៅ អាហ្គូស្តូ ភីណូឆេត ហើយបានធ្វើយុទ្ធនាការ និងបាតុកម្មប្រឆាំងនឹងលោក។ សកម្មភាពទាំងនេះ ក៏បានធ្វើឱ្យអន្តរាយដល់ការគាំទ្រលើភីណូឆេតផងដែរ ដោយសារតែសមាជិកនៃរបបយោធារបស់លោកក៏លែងមានភក្តីភាពចំពោះរូបលោកខណៈដល់ចំណុចកំពូលនៃវិបត្តិ ហើយលោកក៏ត្រូវបានបង្ខំឱ្យចុះចេញពីអំណាច
- ចាប់ពីឆ្នាំ១៩៨០ ដល់ ១៩៨៩ ជនជាតិប៉ូឡូញ រៀបចំសហជីពពាណិជ្ជកម្មឯករាជ្យ ជាផ្នែកមួយនៃចលនាសាមគ្គីភាព និងយកប្រទេសរបស់ខ្លួនចេញពីការគ្រប់គ្រងរបស់សូវៀត
- ក្នុងឆ្នាំ១៩៨៩ បាតុកម្ម និងកូដកម្មដែលត្រូវបានស្គាល់ថាជា បដិវត្តន៍វេលវេត បាននាំឱ្យមានការប្តូរដោយសន្តិវិធីពីរបបកុំម្មុយនីស្ត នៅឆេកូស្លូវ៉ាគី។ សកម្មភាពស្រដៀងគ្នានេះ បាននាំឱ្យមានការផ្លាស់ប្តូររបបដោយសន្តិវិធីផងដែរដូចជា នៅអាល្លឺម៉ង់ខាងកើត និងនៅឡាត់វី លីទុយអានី និងអេស្តូនៀ នៅឆ្នាំ១៩៩១
- កូដកម្ម ពហិកា ការបដិសេធច្បាប់រដ្ឋ និងទណ្ឌកម្មពីខាងក្រៅ ចាប់ផ្តើមក្នុងទស្សវត្សរ៍ទី៨០ បានដើរតួយ៉ាងសំខាន់ក្នុងការបញ្ឈប់ការរើសអើងជាតិសាសន៍ នៅអាហ្វ្រិកខាងត្បូង នៅដើមទស្សវត្សរ៍ទី៩០

- ក្នុងបណ្តាឆ្នាំទាំងនេះ ជនជាតិស៊ែប៊ី (ឆ្នាំ២០០០) ជនជាតិហ្សកហ្ស៊ី (ឆ្នាំ២០០៣) និងជនជាតិអ៊ុយក្រែន (ឆ្នាំ២០០៤) បញ្ចប់នូវការដឹកនាំដោយអំណាចផ្តាច់ការតាមរយៈការកៀរគរដើម្បីការពារ ឬប្រឆាំងនឹងលទ្ធផលបោះឆ្នោតក្លែងបន្លំ
- នៅក្នុងឆ្នាំ២០០៥ ជនជាតិលីបង់ បានបញ្ចប់ការកាន់កាប់ប្រទេសដោយកងយោធានៃប្រទេសស៊ីរី តាមរយៈការធ្វើបាតុកម្មអហិង្សាទ្រង់ទ្រាយធំ
- នៅក្នុងឆ្នាំ២០០៦ ជនជាតិនេប៉ាល់ បានចូលរួមក្នុងការមិនគោរពទ្រង់ទ្រាយធំ និងបង្ខំឱ្យមានការស្តារឡើងវិញនៃច្បាប់ស៊ីវិល
- ចាប់ពីឆ្នាំ២០០៧ ដល់ ២០០៩ នៅក្នុងអំឡុងនៃកុបកម្មហិង្សា និងនៅចំពោះមុខមេដឹកនាំយោធា មេធាវីជនជាតិប៉ាគីស្ថាន ក្រុមអង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋសាមញ្ញទទួលបានជោគជ័យ ក្នុងការជំរុញឱ្យមានការស្តារឡើងវិញនៃប្រព័ន្ធយុត្តិធម៌ឯករាជ្យ និងលុបចោលច្បាប់ដាក់ប្រទេសក្នុងគ្រាអាសន្ន។

## ប្រសិនបើប្រជាពលរដ្ឋមិនគោរព អ្នកដឹកនាំមិនអាចដឹកនាំបានទេ

ចលនាទាំងអស់នេះ និងចលនាតស៊ូស៊ីវិលដទៃទៀត បានទទួលជោគជ័យដោយសារតែចលនាទាំងនេះផ្អែកលើគោលគំនិតមូលដ្ឋាននៃអំណាច៖ ដែលថាគ្រប់ស្ថាប័ន អង្គភាព និងប្រព័ន្ធទាំងអស់នៅក្នុងសង្គមពឹងផ្អែកលើការព្រមព្រៀង ការសហការណ៍ និងការគោរពជាបន្តបន្ទាប់ ពីប្រជាពលរដ្ឋសាមញ្ញជាច្រើន។ ដូច្នេះ ប្រសិនបើប្រជាពលរដ្ឋសម្រេចថានឹងមិនផ្តល់ការព្រមព្រៀង និងសហការណ៍ ក្នុងវិធីមួយដែលមានការរៀបចំ និងមានយុទ្ធសាស្ត្រ នោះពួកគេនឹងអាចកាន់កាប់អំណាចដោយបង្ខំបាន។ នៅពេលដែលប្រជាពលរដ្ឋមិនគោរព នោះប្រធានាធិបតី ចៅហ្វាយក្រុង ប្រធានក្រុមហ៊ុន ឧត្តមសេនីយ និង «អ្នកកាន់អំណាច» ដទៃទៀត នឹងមិនអាចដឹកនាំដោយអំណាចដែលគ្មានការត្រួតពិនិត្យបាននោះទេ។

យុទ្ធវិធីអហិង្សា ដូចជា កូដកម្ម ពហិការ បាតុកម្មទ្រង់ទ្រាយធំ ការបដិសេធច្បាប់រដ្ឋ ការបង្កើតស្ថាប័នស្រប និងសកម្មភាពបែបច្នៃប្រឌិតរាប់រយទៀត ជាឧបករណ៍សំខាន់ដែលត្រូវបានប្រើដើម្បីធ្វើការងារនេះ។ វិធីទាំងនេះមិនមែនត្រូវបានប្រើដោយក្នុងហេតុផលសីលធម៌នោះទេ ប៉ុន្តែ គឺដោយសារតែហេតុផលប្រាកដនិយមទៅវិញទេ។ អ្នកខ្លះដែលបានអនុវត្តនូវការតស៊ូដោយពលរដ្ឋ បានឃើញយុទ្ធសាស្ត្រស្រដៀងគ្នានេះថា ការប្រើប្រាស់បានផលក្នុងប្រទេសដទៃ ឬក្នុងប្រទេសខ្លួនឯងក្នុងប្រវត្តិសាស្ត្រ និងទទួលស្គាល់ថាប្រភេទនៃការតស៊ូបែបនេះ មានការរំពឹងទុកខ្លាំងបំផុតថាទទួលជោគជ័យ ក្នុងចំណោមជម្រើសផ្សេងៗដែលពួកគេមាន។

## ជំនាញ និងលក្ខខណ្ឌ

យ៉ាងណាក៏ដោយ ក្នុងចំណោមចលនាអហិង្សាដែលជោគជ័យគួរឱ្យយកតម្រាប់តាមនេះ ប្រវត្តិសាស្ត្រ និងពិភពលោកបច្ចុប្បន្ន ក៏បានផ្តល់នូវឧទាហរណ៍នៃចលនាដែលបរាជ័យ ឬក៏មិនបានផលផងដែរ។ ពិភពលោកបានមើលឃើញនូវបដិវត្តន៍អហិង្សារបស់ប៉ូឡូញ និងឆេកូស្លូវ៉ាគី ក្នុងឆ្នាំដែលពួកគេក៏ឃើញនូវការសម្លាប់រង្គាលនៅទីលានធានអានមិន។ ក្នុងទស្សវត្សរ៍ចុងក្រោយ ប្រជាពលរដ្ឋជាច្រើននាក់បានប្រើប្រាស់យុទ្ធវិធីអហិង្សានៅភូមា ស៊ីមបាវេ អេហ្ស៊ីប និងអ៊ីរ៉ង់ ប៉ុន្តែគោលដៅនៃចលនាទាំងនោះមិនទាន់បានសម្រេចនោះទេ មកទល់បច្ចុប្បន្ននេះ។ នៅក្នុងកិច្ចប្រឹងប្រែងទាមទារសិទ្ធិស្វ័យសម្រេចនៅ ទីម័រខាងកើត ការតស៊ូដោយពលរដ្ឋគឺខ្វះមិនបាននោះទេ ប៉ុន្តែខណៈដែលការតស៊ូនេះបានជួយជំរុញនូវចលនាប្រជាពលរដ្ឋប្រឆាំងនឹងជនឈ្លានពាននៅគ្រប់ទីកន្លែងដូចជា នៅប៉ាលេស្ទីន ប៉ាពួខាងលិច សាហារ៉ាខាងលិច និងទីបេ ជាដើម ដែលកិច្ចខិតខំប្រឹងប្រែងទាំងអស់នោះនៅមិនទាន់សម្រេចនៅឡើយ។

តើចំណុចអ្វីខ្លះដែលធ្វើឱ្យមានភាពខុសគ្នារវាងករណីទាំងនេះ និងករណីផ្សេងទៀត?

កត្តាដែលធ្វើឱ្យចលនានេះ និងចលនាដទៃទៀត ជោគជ័យ ឬក៏បរាជ័យ គឺជាប្រធានបទមួយដែលសមហេតុផល ហើយមនុស្សដែលទទួលបានព័ត៌មានគ្រប់គ្រាន់អាចមិនយល់ស្រប។[1] ស្ថានភាពនីមួយៗ មានភាពស្មុគស្មាញខ្លាំង ហើយការបង្កើតហេតុផលផ្ទាល់គឺពិបាកណាស់។ អំណះអំណាងដែលខ្ញុំតែងតែបានឮជាញឹកញាប់ មកពីបញ្ញវន្ត អ្នកកាសែត និងអ្នកដទៃទៀត គឺថាគន្លង និងលទ្ធផលនៃចលនាទាំងនេះ និងចលនាអហិង្សាដែលលេចធ្លោផ្សេងទៀត ភាគច្រើនត្រូវបានកំណត់ដោយរចនសម្ព័ន្ធ លក្ខខណ្ឌ និងកាលៈទេសៈពិសេសដោយឡែកដែលចលនានីមួយៗដំណើរការ។

[1] សម្រាប់គោលបំណងនៃអត្ថបទនេះ ខ្ញុំផ្តល់និយមន័យដល់ចលនា «ជោគជ័យ» ជាចលនាទាំងឡាយណាដែលអាចសម្រេចបាននូវគោលបំណងដែលបានកំណត់ទុក ហើយចលនា «បរាជ័យ» ជាចលនាទាំងឡាយណាដែលមិនសម្រេចបានគោលបំណងដែលបានកំណត់ទុក។ មានធាតុផ្សំដែលទាក់ទងនឹងពេលវេលាក្នុងនិយមន័យនេះផងដែរ។ ចលនាជោគជ័យមួយ អាចនឹងសម្រេចបានគោលបំណងដែលបានកំណត់ទុក (ដូចជា ចលនាទឹកក្រូចនៅអ៊ុយក្រែន ឆ្នាំ ២០០៤) ប៉ុន្តែ បញ្ហាប្រឈមក្នុងការចំណាយពេលជាច្រើនឆ្នាំដើម្បីការសម្រេចបាននៃចលនានោះ អាចបណ្តាលឱ្យមានការធ្លាក់ដុនដាបម្តងទៀត (សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងករណីអ៊ុយក្រែន សូមអាន អត្ថបទថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០ «ការតស៊ូបន្ទាប់ពីអំណាចប្រជាពលរដ្ឋបានឈ្នះ» សរសេរដោយ អូលេណា ត្រេងុប និង អុកសាណា ហ្សុលយ៉ា នៅលើ openDemocracy)។ ផ្ទុយមកវិញ ចលនាដែលខកខានក្នុងការសម្រេចបានគោលបំណងដែលកំណត់ទុក (ដូចជា ចលនាគាំទ្រប្រជាធិបតេយ្យរបស់ចិន ក្នុងឆ្នាំ ១៩៨៩) អាចបង្កើតឱ្យមានផលប៉ះពាល់បន្ទាប់បន្សំក្នុងរយៈពេលច្រើនឆ្នាំក្រោយ ដែលជួយជំរុញដល់ចលនាផ្សេងៗ (សម្រាប់ព័ត៌មានបន្ថែមពីករណីរបស់ចិន សូមអានអត្ថបទថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០ «មតិប្រតិកម្មលើការបង្ក្រាបនៅប្រទេសចិន» ដោយ ឡេស្ទ័រ ខឺត នៅលើ openDemocracy)។ ខណៈពេលដែលមិនចាំបាច់ត្រូវផ្លាស់ប្តូរការចាត់ចំណាត់ថ្នាក់នៃចលនាជាក់លាក់មួយថា «ជោគជ័យ» ឬ » បរាជ័យ» ផលប៉ះពាល់ដែលកើតមានតាមក្រោយ អាចមានអនុភាព ហើយដូច្នេះមានភាពគួរឱ្យកត់សម្គាល់រៀងៗខ្លួន។

ឧទាហរណ៍ អំណះអំណាងខ្លះបានលើកឡើងថា ចលនាអហិង្សាមានប្រសិទ្ធភាពតែក្នុងសង្គមណាដែលជនគាបសង្កត់ មិនមានបំណងប្រើប្រាស់កងកម្លាំងដែលអាចបណ្តាលឲ្យគ្រោះថ្នាក់ដល់ជីវិត។ ចំណែកឯអ្នកដទៃទៀតលើកឡើងថា លក្ខខណ្ឌសេដ្ឋកិច្ចជាក់លាក់មួយចំនួន (ដូចជា មនោគមវិទ្យាសេដ្ឋកិច្ចកម្រិតប្រាក់ចំណូល ការបែងចែកទ្រព្យសម្បត្តិ វត្តមាននៃវណ្ណៈកណ្តាល) និងកម្រិតនៃការអប់រំ មានសារៈសំខាន់ខ្លាំងសម្រាប់ការជោគជ័យនៃចលនាទាំងនោះ។ តែក៏នៅមានអ្នកឯទៀតអះអាងដែរថា តួនាទីរបស់ប្រទេសមហាអំណាច និងអនុត្តរភាពតំបន់លុបលើសារៈសំខាន់នៃអញ្ញត្តិផ្សេងៗទៀត ក្នុងការកំណត់នូវលទ្ធផលនៃចលនា។ ចំនួននៃរចនាសម្ព័ន្ធ និងលក្ខខណ្ឌបន្ថែមដែលមនុស្សម្នាក់អាចសំអាងបាន ដូចជាភាពចម្រុះនៃជាតិសាសន៍ ប្រវត្តិនយោបាយ និងវប្បធម៌ ចំនួនប្រជាពលរដ្ឋ ទំហំទឹកដី មានច្រើន ហើយដើម្បីឱ្យប្រាកដ លក្ខខណ្ឌទាំងអស់នេះអាចជះឥទ្ធិពលដល់ដំណើរនៃចលនា។

ក្នុងចំណុចផ្ទុយនៃកត្តារចនាសម្ព័ន្ធ និងលក្ខខណ្ឌ គឺកត្តាដែលផ្អែកលើជំនាញរបស់ចលនាក្នុងការបង្កើតជម្លោះ គឺអ្វីដែលបញ្ញវន្តហៅថា «ភ្នាក់ងារ»។ ជំនាញ និងភ្នាក់ងារ សំដៅលើអញ្ញត្តិដែលចលនាមួយអាចមានលទ្ធភាពត្រួតត្រាបានខ្លះ ៖ តើសកម្មភាពយុទ្ធសាស្ត្រអ្វីខ្លះដែលចលនាមួយជ្រើសយក តើភាសាអ្វីដែលចលនាប្រើប្រាស់ដើម្បីកៀរគរអ្នកចូលរួម និងធ្វើឱ្យពួកគេនៅបន្តពាក់ព័ន្ធ របៀបនៃការកសាងសម្ព័ន្ធមិត្ត កន្លែងណា និងរបៀបណាដែលចលនាដៅមុខសញ្ញាលើបច្ចាមិត្ត និងការសម្រេចចិត្តជាច្រើនទៀតដែលពាក់ព័ន្ធនឹងការចូលរួមក្នុងការតស៊ូដោយពលរដ្ឋ។

តាមទស្សនៈរបស់ខ្ញុំ កត្តាដែលផ្អែកលើជំនាញ ជាញឹកញាប់តែងតែមិនសូវបានយកចិត្តទុកដាក់ ឬក៏មើលរំលងដោយអ្នកដែលពាក់ព័ន្ធ និងវិភាគចលនាអហិង្សា។ ហេតុអ្វីបានជាដូច្នេះ គឺហួសពីវិសាលភាពនៃអត្ថបទនេះ ប៉ុន្តែហេតុផលមួយប្រហែលជាការសង្ស័យ ឬក៏មិនដឹងពីសំអាងដែលសកម្មភាពអហិង្សាអាចផ្អែកបាន ដែលតាមរយៈការផ្លាស់ប្តូរនៃអាកប្បកិរិយាសមូហភាព   អំណាចត្រូវបានទាញយកពីបច្ចាមិត្តដែលមានអំណាចចាក់ឫស និងគាបសង្កត់មកឱ្យចលនាដោយពលរដ្ឋ។ ផ្ទុយមកវិញ ពួកគេសន្មតថាច្បាស់ជាមានអញ្ញត្តិថេរ ឬក៏កាលៈទេសៈខុសប្រក្រតី ដែលអាចធ្វើឱ្យចលនានេះអាចទៅរួចដូចអ្វីដែលបានកើតឡើង។

ប៉ុន្តែ យើងអាចគោរពតួនាទីនៃរចនាសម្ព័ន្ធ និងលក្ខខណ្ឌដែលមានឥទ្ធិពលលើគន្លង និងលទ្ធផលនៃចលនាអហិង្សា ដោយពុំបាននិយាយសម្រាលពីសារៈសំខាន់នៃភ្នាក់ងារ និងជំនាញ។ ជាការពិតណាស់ ភ្នាក់ងារ និងជំនាញអាចធ្វើឱ្យមានការខុសប្លែក ហើយក្នុងករណីខ្លះអាចធ្វើឱ្យចលនាអាចយកឈ្នះបញ្ចៀស ឬផ្លាស់ប្តូរលក្ខខណ្ឌមិនអំណោយផល។

សារៈសំខាន់ និងពេលខ្លះភាពល្អដាច់គេ នៃជំនាញ និងភ្នាក់ងារគឺត្រូវបានពិចារណាពីចំណេះដឹងទូទៅក្នុងរបៀបផ្សេងទៀត ដូចជា ការគិតពីអាជីវកម្ម ឬក៏យោធា។ ហេតុអ្វីបានជាការតស៊ូដោយអហិង្សាខុសប្លែកក្នុងករណីនេះ? ឧត្តមសេនីយយោធា ឬក៏ប្រធានសាជីវកម្មអាចនឹងសើច ប្រសិនបើត្រូវបានប្រាប់ថា យុទ្ធសាស្ត្រ មានសារៈសំខាន់តិចតួចចំពោះលទ្ធផលនៃការខិតខំរបស់ពួកគេ។ សិល្បៈសង្គ្រាមបុរាណរបស់ ស៊ុនអ៊ូ មិនត្រូវបានគេស្គាល់នោះទេប្រសិនបើមនុស្សគិតថាលទ្ធផលនៃការប្រកួត និងទំនាក់ទំនងដែលមានជម្លោះតែងតែត្រូវបានកំណត់ទុកជាមុនដោយលក្ខខណ្ឌសម្ភារៈ។

ដើម្បីត្រលប់ទៅរកសំណួរបើក នៃអត្ថបទនេះ តើអ្វីដែលធ្វើឱ្យការតស៊ូអហិង្សាមានប្រសិទ្ធភាព? យើងអាចចាប់ផ្តើមរកចម្លើយតាមរយៈការមើលលើជម្រើសយុទ្ធសាស្ត្រ និងការអនុវត្តល្អៗ ដែលប្រមូលបានមកពីចលនានៅក្នុងប្រវត្តិសាស្ត្រ។ មានកត្តាផ្អែកលើភ្នាក់ងារ និងជំនាញជាច្រើន ដែលអាចជះឥទ្ធិពលដល់លទ្ធផលនៃចលនា ប៉ុន្តែ (ដើម្បីភាពងាយស្រួល) ប្រសិនបើយើងច្រោះយកចំណុចសំខាន់ៗមួយចំនួនមានបីចំណុចដែលចលនាអហិង្សាទទួលជោគជ័យដូចជា ៖ សាមគ្គីភាព ផែនការ និងវិន័យអហិង្សា។

## សាមគ្គីភាព ផែនការ និងវិន័យ

មើលមួយក្រលេក សារៈសំខាន់នៃគុណលក្ខណៈទាំងនោះហាក់ដូចជាបង្ហាញឱ្យឃើញដោយខ្លួនឯង។ ប៉ុន្តែ ជម្រៅនៃគុណលក្ខណៈទាំងនេះ និងភាពជាប់ពាក់ព័ន្ធសំខាន់ទាំងនេះ ពេលខ្លះត្រូវបានមើលរំលងនៅពេលដែលបុគ្គលម្នាក់មើលឃើញចលនាទាំងនោះនៅក្នុងកម្រិតយុទ្ធសាស្ត្រ និងលម្អិតលើសលុប។ ជាតុផ្សំនីមួយៗគួរតែទទួលបានការពណ៌នាលម្អិត។

សាមគ្គីភាព មានសារៈសំខាន់ពីព្រោះចលនាអហិង្សា ទាញកម្លាំងពីការចូលរួមរបស់ប្រជាពលរដ្ឋមកពីផ្នែកចម្រុះគ្នាក្នុងសង្គម។ និយាយឱ្យសាមញ្ញ ៖ តួលេខគឺសំខាន់។ មនុស្សកាន់តែច្រើនគាំទ្រនូវចលនាណាមួយ ចលនានោះកាន់តែមានភាពស្របច្បាប់ មានអំណាច និងបណ្តុំនៃយុទ្ធវិធី។ ដូច្នេះ ចលនាដែលទទួលបានជោគជ័យ នឹងទៅដល់ក្រុមថ្មីនៅក្នុងសង្គមរបស់ពួកគេ ដូចជា បុរស និងស្ត្រី យុវជន មនុស្សពេញវ័យ និងមនុស្សចាស់ ប្រជាពលរដ្ឋនៅក្នុងទីប្រជុំជន និងជនបទ ជនជាតិដើមភាគតិច សមាជិកនៃ

ស្ថាប័នសាសនា កសិករ កម្មករ អ្នកជំនួញ និងអ្នកមានវិជ្ជាជីវៈផ្សេងៗទៀត ទាំងអ្នកមាន វណ្ណៈកណ្តាល និង ក្រុមដែលមានសេដ្ឋកិច្ចទាប ប៉ូលីស ទាហាន និងសមាជិកនៃយុត្តាធិការ ក៏ដូចជា ក្រុមដទៃទៀត។

ចលនាដែលបានជោគជ័យ ក៏នឹងបន្តទៅដល់អ្នកគាំទ្រនៃគូបដិបក្ខ ដោយបានយល់ថាជាកម្លាំងមួយក្នុងចំណោមកម្លាំងនានា នៃការតស៊ូដោយពលរដ្ឋដែលមាននិរន្តភាព ក្នុងការបម្រើឱ្យចក្ខុវិស័យបង្រួបបង្រួម គឺជាសមត្ថភាពក្នុងការនាំឱ្យមានការផ្លាស់ប្តូរភក្តីភាព និងការចុះចូលពីសំណាក់គូបដិបក្ខរបស់ខ្លួន។ ឧទាហរណ៍ ការរារាំងរបស់ប្រជាពលរដ្ឋ ក្នុងចលនាប្រឆាំងការរើសអើងពូជសាសន៍នៅអាហ្វ្រិកខាងត្បូង រួមផ្សំនឹងការអំពាវនាវឱ្យមានការបង្រួបបង្រួមជាតិ អាចប្រមូលការគាំទ្រដ៏ទូលំទូលាយ និងបង្កើតសាមគ្គីភាពដើម្បីជាមូលហេតុនៃការផ្លាស់ប្តូរ ទោះបីជានៅក្នុងចំណោមអ្នកគាំទ្រក៏មានជនជាតិស្បែកស ដែលពីមុនបានគាំទ្ររដ្ឋដែលរើសអើងពូជសាសន៍ក៏ដោយ។

អ្នកចូលរួមក្នុងចលនាអហិង្សា ក៏ត្រូវតែធ្វើការសម្រេចចិត្តដ៏ស្មុគស្មាញអំពីដំណើរដែលចលនាពួកគេត្រូវធ្វើដែរ។ **ផែនការយុទ្ធសាស្ត្រ** គឺមានសារៈសំខាន់ខ្លាំងក្នុងការធ្វើបែបនេះ។ ការមិនគិតពីគុណប្រយោជន៍នៃបុព្វហេតុរបស់បុគ្គល ឬការដែលមិនអាចគាំទ្របានផ្នែកសីលធម៌របស់គូបដិបក្ខ ការគាបសង្កត់ជាទូទៅមិនអាចត្រូវបានយកឈ្នះតែម្នាក់ឯងដោយឯកឯង និងតាមរយៈសកម្មភាពតស៊ូជាបន្តបន្ទាប់ដោយមិនបានគិតទុកជាមុននោះទេ បើទោះជាសកម្មភាពទាំងនោះត្រូវបានអនុវត្តបានយ៉ាងល្អក៏ដោយ។ ផ្ទុយមកវិញ ចលនាទទួលបានការអូសទាញ នៅពេលដែលពួកគេរៀបចំផែនការពីរបៀបនៃការតស៊ូដោយពលរដ្ឋអាចត្រូវបានរៀបចំ និងអនុម័តជាប្រព័ន្ធដោយមនុស្សនៅក្នុងសង្គមដើម្បីទទួលបានគោលដៅដែលបានកំណត់ និងផ្តោតជាសំខាន់។ ការសម្រេចថាតើត្រូវប្រើប្រាស់យុទ្ធវិធីអ្វីខ្លះ និរបៀបដែលត្រូវរៀបចំឲ្យមានលំដាប់លំដោយនៃយុទ្ធវិធីទាំងនោះ ការបង្កើតសំណើធ្វើឱ្យមានសកម្មភាពឡើងវិញ ដើម្បីផ្លាស់ប្តូរផ្អែកលើបំណងប្រាថ្នា និងភាពអយុត្តិធម៌របស់ប្រជាពលរដ្ឋ ដែលចលនានេះមានគោលបំណងជាតំណាង ការធ្វើផែនការថាតើត្រូវកំណត់គោលដៅលើបុគ្គល និងក្រុមណា ជាមួយនឹងយុទ្ធវិធី និងតើគោលបំណងអ្វីខ្លះសម្រាប់រយៈខ្លី មធ្យម និងរយៈពេលវែង ដើម្បីឲ្យសម្រេចបាន ហើយនិងការកសាងបណ្តាញទំនាក់ទំនងដើម្បីអាចឱ្យសម្ព័ន្ធអាចចរចា និងកសាង គឺគ្រាន់តែជាបញ្ហាមួយចំនួននៅជុំវិញអ្វីដែលចលនាអហិង្សាត្រូវតែមានយុទ្ធសាស្ត្រប្រកបដោយភាពច្នៃប្រឌិត។ ការធ្វើដូច្នេះ តម្រូវឱ្យមានការវិភាគគ្រប់ជ្រុងជ្រោយ លើស្ថានភាពដែលការតស៊ូអហិង្សាកើតឡើង។ ជាផ្នែកមួយនៃដំណើរការធ្វើផែនការ ចលនាដែលមានប្រសិទ្ធភាព ទាំងផ្លូវការ និងមិនផ្លូវការ ប្រមូលនូវព័ត៌មាន ស្តាប់ប្រជាពលរដ្ឋនៅសហគមន៍ និងវិភាគពីខ្លួនឯង ពីគូបដិបក្ខ និងភាគីទីបីដែលមិនបានគាំទ្រទៅខាងណាមួយ ជាបន្តបន្ទាប់ក្នុងដំណើរការនៃជម្លោះ។

ជាចុងក្រោយ យុទ្ធសាស្ត្រគឺអាចមានប្រសិទ្ធភាព ប្រសិនបើអនុវត្តទៅនៅក្នុងវិធីមួយដែលមានវិន័យ។ ហានិភ័យធំបំផុត សម្រាប់ការបរាជ័យនៃវិន័យ ក្នុងចលនាអហិង្សា គឺថាសមាជិកខ្លះអាចនឹងប្រើហិង្សា។ ដូច្នេះ វិន័យអហិង្សា លទ្ធភាពរបស់មនុស្សក្នុងការរក្សាភាពអហិង្សា ទោះបីជាមានការបង្ករឿងក៏ដោយ គឺជាញឹកញាប់ត្រូវតែបន្តពង្រឹងដល់អ្នកចូលរួម។ មានហេតុផលជាក់លាក់មួយចំនួនសម្រាប់ករណីនេះ។ ហេតុការណ៍ហិង្សាដោយសមាជិកនៃចលនាមួយ អាចនឹងទម្លាក់នូវភាពស្របច្បាប់នៃចលនានោះយ៉ាងគំហុគ ហើយស្របពេលជាមួយគ្នានោះ នឹងផ្តល់ជាលេសសម្រាប់គូបដិបក្ខក្នុងការបង្រ្កាប។ បន្ថែមពីលើនោះ ចលនាមួយដែលអហិង្សាតាំងពីដើមរហូតមក មានឱកាសច្រើនក្នុងការអំពាវនាវឱ្យមានការចូលរួមយ៉ាងទូលំទូលាយពីសម្ព័ន្ធមិត្តដែលមានសក្តានុពលផ្សេងៗ រួមទាំង អ្នកគាំទ្ររបស់គូបដិបក្ខផងដែរ តាមរយៈដំណើរការនៃការតស៊ូ។

ការស្វែងរកយ៉ាងពេញលេញស្តីអំពីគុណលក្ខណៈទាំងអស់នេះ មានច្រើនរាប់មិនអស់ ហើយប្រធានបទនៃចំណុចល្អៗនៃការតស៊ូអហិង្សា ហើយនឹងកំពុងតែទទួលបានការសិក្សាជាប្រព័ន្ធជាបន្តបន្ទាប់។ ចលនានីមួយៗ ដែលលេចឡើង បន្ថែមនូវចំណេះដឹងជាច្រើនដល់ការស្វែងយល់ជាសមូហភាពអំពីបាតុភូតនេះ ប៉ុន្តែ នៅមានជាច្រើនទៀតទាក់ទិននឹងសិល្បៈ និងវិទ្យាសាស្ត្រនៃទម្រង់សកម្មភាពនយោបាយ និងសង្គម ដែលនៅមិនទាន់បានរៀបចំ និងបង្កើត។
ប៉ុន្តែគុណលក្ខណៈទាំងបីនេះ សាមគ្គីភាព ផែនការ និងវិន័យ គឺមិនចេះចប់ ហើយដូច្នេះផ្តល់នូវក្របខណ្ឌទូទៅដែលសមាជិក និងអ្នកគាំទ្រនៃចលនា ក៏ដូចជាអ្នកដែលរាយការណ៍ និងអ្នកសិក្សាពីចលនាទាំងនេះ អាចវាយតម្លៃបានយ៉ាងឆាប់រហ័សពីស្ថានភាពនៃចលនានីមួយៗ។ តើចលនានេះមានការបង្រួបបង្រួមទេ ? តើមានផែនការទេ ? តើមានវិន័យទេ ? សកម្មភាពនៃបុគ្គលទាំងឡាយណាដែលប្រកាន់ខ្ជាប់នូវគោលការណ៍ទាំងអស់នេះ ក្នុងសកម្មភាពអហិង្សា បានត្រួសត្រាយផ្លូវទៅកាន់ពិភពលោកដែលកាន់តែមានសន្តិភាព និងយុត្តិធម៌។ អនាគតនឹងត្រូវកំណត់ដោយអ្នកដែលបន្តធ្វើបែបនេះដែរ។